# តើមានអ្វីធ្វើឲ្យអ្នក មានសម្រស់ស្អាត ?



មានពេលមួយ ឡេឡា(Lela)បានវិលត្រឡប់មកផ្ទះវិញ ទាំងទឹកភ្នែកហូររហាម។ មិត្តរួមថ្នាក់របស់នាងមួយចំនួន បានចម្អកឲ្យនាង នៅតាមបណ្តាញសង្គម ក៏ដូចជានៅក្នុងថ្នាក់រៀន។ ពួកគេបានហៅនាងថា "ឈើចាក់ធ្មេញ" ហើយបានសើចចម្អកឲ្យរូបរាងដ៏ស្គមស្គាំងរបស់នាង។ តាមពិត ឡេឡាមានជម្ងឺម្យ៉ាងដែលបានធ្វើឲ្យនាងស្គម ស្ទើរតែមិនអាចឡើងគីឡូបាន។ ទោះនាងបានញ៉ាំបាយច្រើនប៉ុណ្ណា ក៏នៅតែស្គម។




TIMTAM
ORIGINAL

ឡេឡាក៏បានព្យាយាមធ្វើឲ្យខ្លួនឯង "មានសម្រស់ស្អាត" ដោយព្យាយាមញ៉ាំអាហារកាន់តែច្រើនឡើងៗ។ បន្ទាប់មក ប្រព័ន្ធបំលែងអាហារនៅក្នុងខ្លួននាង ក៏បានចាប់ផ្តើមផ្លាស់ប្តូរ។ ភ្លាមៗនោះ នាងក៏បានឡើងគីឡូយ៉ាងឆាប់រហ័ស។ ក្នុងរយៈពេលតែ២ឆ្នាំ នាងបានឡើងគីឡូ ពី៤០គីឡូទៅ៧០គីឡូ។

ឥឡូវនេះ គេប្រាប់ឡេឡាថា នាងធាត់ណាស់។ មនុស្សនៅជុំវិញខ្លួននាងក៏បានសើចចម្អកឲ្យមាឌដ៏ធំរបស់នាង ហើយនាងក៏មានអារម្មណ៍ថា នាងកំពុងតែទទួលរងសម្ពាធឲ្យផ្លាស់ប្តូររាងម្តងទៀត។ នាងក៏បានតមអាហារ ហើយហាត់ប្រាណយ៉ាងស្វិតស្វាញ ប៉ុន្តែ នាងដឹងថា នាងពិបាកផ្លាស់ប្តូរ ឲ្យត្រូវតាមស្តង់ដានៃសម្រស់របស់មនុស្សនៅជុំវិញខ្លួននាង។ ទោះនាងធ្វើយ៉ាងណាក៏ដោយ នាងហាក់ដូចជា មិនអាចមានភាព "ល្អគ្រប់គ្រាន់"។ តើនាងនឹងមានភាពទាក់ទាញល្មមនឹងអាចមានគេស្រឡាញ់ ហើយរៀបការជាមួយនាងឬទេ? តើនឹងមានថ្ងៃដែលគេនឹងឲ្យតម្លៃនាង ដោយមិនខ្វល់អំពីរូបរាងរបស់នាងឬទេ?




size
10
Beautiful

តើអ្នកធ្លាប់មានបទពិសោធន៍ដូចទ្បេទ្បាឬទេ? តើអ្នកមានអារម្មណ៍ថា អ្នកត្រូវផ្លាស់ប្តូររូបរាង្គ គ្រាន់តែដើម្បីឲ្យសប្បាយចិត្តឬ? តើគេធ្លាប់សើចចម្អកឲ្យមាឌ រូបសម្បត្តិ ឬសំលៀកបំពាក់របស់អ្នកឬទេ? តើអ្នកធ្លាប់ឆ្ងល់ឬទេថា ជីវិតរបស់មនុស្សមានអ្វីៗដែលលើសពីនេះទៀត គឺមិនមែនសម្រាប់បង្ហំខ្លួនឯងឲ្យមានរូបសម្រស់ "ស្អាត" ដើម្បីឲ្យគេស្រឡាញ់ និងទទួលស្គាល់នោះទេ?





ទោះនាងខិតខំយ៉ាងណា
ក៏ដោយ នាងនៅតែមាន
អារម្មណ៍ថា នាងនៅតែ
មិនអាចផ្គាប់ចិត្តអ្នកដទៃ។



## ការដេញតាមភាពស្រស់ស្អាត :

តើអ្នកដទៃគិតយ៉ាងណាចំពោះអ្នក?

**ខ្ញុំចាំថា កាលខ្ញុំស្ថិតក្នុងអំឡុងពេលនៃការចែចង់ជាមួយមិត្តប្រុសខ្ញុំ ខ្ញុំបានព្យាយាមរក្សារាងឲ្យនៅស្គម ហើយមិនដែលចេញពីផ្ទះ ដោយមិនបានផាត់មុខ និងតុបតែងខ្លួនឡើយ។ បន្ទាប់ពីយើងបានបែកគ្នា គាត់ប្រាប់ខ្ញុំថា តាមពិត គាត់ចង់ឲ្យខ្ញុំមានរូបរាង្គធាត់ជាងនេះបន្តិច ហើយមានមុខ "បែបធម្មជាតិ" ដោយមិនមានលាបម្សៅ ម៉ាស់ការ៉ា ឬក្រែមឡើយ។ មុននោះ ខ្ញុំមិនដឹងសោះថា យើងមានទស្សនៈខុសគ្នាយ៉ាងនេះ អំពីសម្រស់។ ខ្ញុំគិតថា ខ្ញុំបានព្យាយាមធ្វើឲ្យខ្លួនឯងមានរូបសម្រស់ស្អាតសម្រាប់គាត់ ប៉ុន្តែ តាមពិត គាត់ចង់ឲ្យខ្ញុំមាន "ភាពសាមញ្ញ" ទៅវិញទេ។**

តាមវចនានុក្រម សម្រស់គឺជាភាពស្រស់ស្អាត ដែលមាននៅក្នុងផ្នែកទាំងអស់របស់មនុស្សម្នាក់ ឬវត្ថុណាមួយ គឺមិនមែនតែនៅក្នុងរូបសម្បត្តិខាងក្រៅប៉ុណ្ណោះឡើយ។ ប៉ុន្តែ បណ្តាញសង្គម ទស្សនាវដ្តី និងខ្សែភាពយន្តច្រើនតែផ្តោតទៅលើតែរូបសម្បត្តិ ដែលជាសម្បកខាងក្រៅរបស់មនុស្ស។

**តាំងពីក្មេងមក គេប្រាប់យើងថា មនុស្សស្រីគួរតែមានរាងស្លីម និងស្បែកសរស្អាត។** ហេតុនេះហើយ មនុស្សជាច្រើនជឿថា យើងចាំបាច់មានរូបរាងបែបណាមួយ ដើម្បីឲ្យមានភាពទាក់ទាញ។ ការនេះបានធ្វើឲ្យយើងពិបាកចូលក្នុងចំណោមគេឲ្យចុះ ហើយថែមទាំងមានផលប៉ះពាល់មកលើទស្សនៈដែល

យើងមានចំពោះខ្លួនយើងផងដែរ។

នៅសាលារៀន ខ្ញុំបានទទួលឥទ្ធិពលពីមិត្តភក្តិរបស់ខ្ញុំ ដែលខិតខំរក្សារាងឲ្យនៅស្លីម។ ទន្ទឹមនឹងនោះ ម្តាយរបស់ខ្ញុំក៏ចាប់ផ្តើមតមអាហារផងដែរ។ ពេលណាគាត់អាចសម្រកទម្ងន់ ដោយជោគជ័យ គាត់ក៏បានទទួលការសរសើរជាច្រើន ដែលធ្វើឲ្យខ្ញុំចង់សម្រកទម្ងន់ដែរ។ ដូចនេះ ខ្ញុំក៏បានហាត់ប្រាណច្រើនហួសហេតុ ហើយខ្ញុំក៏បានកំណត់បរិមាណកាឡូរីដែលខ្ញុំត្រូវទទួលទាន ព្រមទាំងថ្លឹងទម្ងន់ខ្លួនឯងជារៀងរាល់ថ្ងៃ។ បន្ទាប់មក ស្ទើរតែមួយពព្រិចភ្នែក ខ្លួនរបស់ខ្ញុំស្រាប់តែហើម។ កាលនោះ ខ្ញុំមិនបានដឹងសោះថា មុនរបស់ខ្ញុំប៉ោង ហើយខ្លួនរបស់ខ្ញុំហើម ដោយសារអាឡែកស៊ី នឹងរបស់អ្វីមួយដែលខ្ញុំបានញាំ។ ទាល់តែដល់ពេលដែលខ្ញុំបានទៅពិនិត្យសុខភាពហើយ ទើបខ្ញុំអាចផ្លាស់ប្តូររបបអាហាររបស់ខ្ញុំ។ ពេលខ្ញុំឆ្លុះកញ្ចក់ ខ្ញុំឃើញក្មេងស្រីកាម៉ាប់ដ៏ឯកោម្នាក់ ដែលកំពុងមានចិត្តស្រេកឃ្លានចង់បានសេចក្តីស្រឡាញ់ និងការទទួលស្គាល់ពីអ្នកដទៃ។





## ការស្រេកឃ្លានភាពស្រស់ស្អាត:

### តើអ្នកយល់ឃើញយ៉ាងណា ចំពោះរូបសម្រស់របស់ខ្លួនឯង?

ពេលដែលអ្នកឆ្លុះកញ្ចក់ តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះខ្លួនឯង? ការស្ទង់មតិស្ត្រីរាប់ពាន់នាក់ នៅទូទាំងពិភពលោក បានរកឃើញថា លើសពី៥០ភាគរយនៃក្មេងស្រីក្នុងវ័យជំទង់ទាំងអស់ មិនពេញចិត្តនឹងរូបរាង និងសម្រស់របស់ខ្លួនឯង។ ពួកគេភាគច្រើននិយាយថា ពួកគេមិនចង់ចេញទៅជួបអ្នកដទៃឡើយ បើសិនជាពួកគេមិនពេញចិត្តនឹងរូបសម្រស់របស់ខ្លួនទេនោះ។ ហើយពួកគេជាច្រើននាក់ជឿថា ពួកគេនឹងមិនមានជោគជ័យឡើយ ព្រោះពួកគេជឿថា ពួកគេមិនមានឱកាស និងមានទំនុកចិត្តដូចនារីដែលមានរូបសម្រស់ស្អាតជាងពួកគេ។

ការដេញតាមភាពល្អឥតខ្ចោះនៃរូបសម្រស់នេះ អាចមានផលប៉ះពាល់មកលើរបៀបដែលយើងធ្វើការ សិក្សា ប្រកួតកីឡា និងការកម្សាន្តសប្បាយផងដែរ។ ពេលណាយើងព្យាយាមស្វែងរកការទទួលស្គាល់ពីអ្នកដទៃ ដោយផ្អែកទៅលើរូបរាងខាងក្រៅរបស់យើង នោះវាហាក់ដូចជាមិនដែលមានភាពគ្រប់គ្រាន់ឡើយ។

ដូចនេះ បញ្ហានេះអាចធ្វើឲ្យយើងមិនចង់ជួបអ្នកដទៃ។ វាអាចនាំឲ្យយើងឲ្យតម្លៃខ្លួនឯង ខ្លាចគេបដិសេធន៍ និងថែមទាំងមានជម្ងឺធ្លាក់ទឹកចិត្តទៀតផង។

ហេតុអ្វីបានជាយើងចាំបាច់ត្រូវបន្តរស់នៅ ដោយខ្វះទំនុកចិត្តយ៉ាងដូចនេះ? តើយើងកំពុងតែព្យាយាមធ្វើឲ្យខ្លួនឯងល្អដូចនរណា?



## បញ្ហារបស់សម្រស់ :

### ការឆ្លុះបញ្ចាំងពិតប្រាកដ

តើអ្នកធ្លាប់មើលគំនូរជីវចលរឿងព្រះនាងព្រិលស និង មនុស្សតឿទាំង៧ទេ? នៅក្នុងរឿងនិទានសម្រាប់កុមារនេះ មានក្សត្រីមួយអង្គ មានសម្រស់ស្អាត តែចិត្តអាក្រក់។ ព្រះនាងបានសួរកញ្ចក់ទិព្វ ជារៀងរាល់ថ្ងៃថា "កញ្ចក់ទិព្វ កញ្ចក់ទិព្វ តើនរណាស្អាតជាងគេនៅលើលោកនេះ?" អស់ជាច្រើនឆ្នាំមកហើយ ដែលកញ្ចក់ទិព្វនោះនៅតែទូលនាងថា នាងជាមនុស្សដែលស្អាតជាងគេ ក្នុងពិភពលោក។ តែថ្ងៃមួយ កញ្ចក់ទិព្វក៏ស្រាប់តែផ្តល់ឲ្យនូវចម្លើយខុសពីមុនថា ព្រះនាងព្រិលស ដែលជាបុត្រីចុងរបស់ព្រះនាង គឺជានារីដែលស្អាតជាងគេបំផុត។ រឿងនេះនៅមានដំណើររឿងបន្តទៀត តែអ្វីដែលសំខាន់នោះគឺ : ទោះក្សត្រីចិត្តអាក្រក់នោះមានសម្រស់ស្អាតយ៉ាងណាក៏ដោយ ក៏នាងត្រូវតែប្រឈមមុខនឹងការពិត ដែលថា រូបកាយរបស់នាងមិនស្ថិតស្ថេរជារៀងរហូតទេ។ សម្រស់ប្រភេទនេះមិនមានភាពយូរអង្វែងទេ។

មិនតែប៉ុណ្ណោះ មនុស្សមានទស្សនៈខុសៗគ្នា អំពីសម្រស់នៃរូបកាយ។ ក្នុងវប្បធម៌ខ្លះ នារីដែលមានរូបរាងធាត់ ត្រូវបានគេមើលឃើញថា គួរឲ្យស្រឡាញ់ជាងនារីដែលមានរូបរាងស្គម

ព្រោះគេគិតថា ស្ត្រីដែលធាត់ គឺបានហូបចុកបរិបូរ គឺទំនងជាមានទ្រព្យសម្បត្តិ សុខភាពល្អ និងមានឋានៈខ្ពស់ជាងនារីដែលស្គម។ ទស្សនៈដែលយើងមានចំពោះសម្រស់ក៏ប្រហែលជាមានការផ្លាស់ប្តូរ ដោយសារការយល់ដឹងរបស់យើង អំពីសម្រស់ គឺមិនមានភាពល្អឥតខ្ចោះទេ។ សម្រស់នៃរូបកាយគឺជាសម្រស់ដែលរាក់កំផែល ដែលមាននៅលើស្បែក គឺគ្រាន់តែជាចំណែកមួយភាគតូច នៃសម្រស់ទាំងមូលរបស់អ្នក។ វាមិនបានឆ្លុះបញ្ចាំង អំពីលក្ខណៈសម្បត្តិ ដែលធ្វើឲ្យអ្នកពិសេស ឬអ្វីដែលពិតជាសំខាន់ ដែលមានដូចជា បុគ្គលិកលក្ខណៈ ចរិយាសម្បត្តិ ជំនាញ និងជាពិសេសទឹកចិត្ត ដែលអ្នកមានចំពោះមនុស្សនៅជុំវិញអ្នក។

សម្រស់របស់អ្នកនឹងមិនផ្តល់ឲ្យអ្នក នូវក្តីអំណរដ៏ស្ថិតស្ថេរឡើយ។ តើហេតុអ្វី? ព្រោះតម្លៃដ៏ពិតរបស់អ្នក មិនស្ថិតនៅក្នុងសម្រស់របស់អ្នកទេ។ វាមិនស្ថិតនៅក្នុងក្រុមដែលរាប់រកអ្នក ចំនួនមនុស្សដែលfollowអ្នកនៅលើ Facebook ឬទំហំនៃខោអាវរបស់អ្នកនោះឡើយ។ តាមពិត ព្រះជាម្ចាស់បានបង្កើតអ្នកមក សម្រាប់អ្វីដែលលើសពីនេះ។


I am
fearfully
&
Wonderfully
made

## ការដេញតាមសម្រស់ពិតប្រាកដ :

## ការមានទស្សនៈថ្មីមួយ

**អ្នកមិនអាចមានភាពល្អឥតខ្ចោះសម្រាប់អ្នកដទៃឡើយ ... ប៉ុន្តែ វាមិនមែនជាបញ្ហានោះទេ។ វាមិនមែនជាបញ្ហាទេ ព្រោះអ្នកមានភាពស្រស់ស្អាតសម្រាប់អង្គបុគ្គលមួយ គឺព្រះ ដែលជាអ្នកបង្កើតអ្នកមក។ ព្រះគម្ពីរប៊ីប ដែលជាគោលជំនឿរបស់គ្រីស្ទបរិស័ទបានចែងថា "ទ្រង់បានបង្កើតយើងមកយ៉ាងគួរកោត គួរអស្ចារ្យ ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់"(ទំនុកដំកើង ១៣៩:១៤)។**

អ្នកមានភាពស្រស់ស្អាត ក្នុងព្រះនេត្រព្រះ ព្រោះព្រះអង្គបានបង្កើតអ្នកមកឲ្យមានរូបភាពដូចព្រះអង្គ។ ព្រះអង្គមិនបានទតមើល ឬវិនិច្ឆ័យអ្នក ដូចអ្នកដទៃឡើយ។ ផ្ទុយទៅវិញ ព្រះអង្គស្រឡាញ់អ្នក ទោះអ្នកជាមនុស្សបែបណាក៏ដោយ ដ្បិតព្រះអង្គបានបង្កើតអ្នកមក ដើម្បីបំពេញគោលបំណងមួយ។ ហើយព្រះអង្គកំពុងតែដឹកនាំអ្នក ឲ្យដើរតាមផ្លូវមួយ ដើម្បីឲ្យអ្នកស្គាល់សម្រស់ពិតប្រាកដរបស់អ្នក និងដឹងថា អ្នកមានតម្លៃប៉ុណ្ណា ក្នុងព្រះនេត្រព្រះអង្គ។

តើយើងអាចស្គាល់ព្រះអង្គ និងចាប់ផ្តើមការធ្វើដំណើរនេះដោយរបៀបណា? ចម្លើយនោះគឺ : តាមរយៈព្រះរាជបុត្រាព្រះអង្គ គឺព្រះយេស៊ូវគ្រីស្ទ ដែលបានយាងចុះមកផែនដី ដើម្បីចាប់កំណើតជាមនុស្ស កាលពីជាង២០០០ឆ្នាំមុន។ កាលព្រះយេស៊ូវយាងមកចាប់កំណើត ព្រះអង្គមានការចាប់អារម្មណ៍ចំពោះអស់អ្នកដែលសង្គមបដិសេធ និងអ្នកដែលគិតថាខ្លួនឯងគ្មានតម្លៃ។ សម្រាប់អ្នកដែលសង្គមបដិសេធ គឺព្រះយេស៊ូវបានទតឃើញថា ពួកគេមានភាពស្រស់ស្អាត ព្រោះព្រះអង្គបានបង្កើតពួកគេមក។

បើអ្នកកំពុងតែស្វែងរកសម្រស់ ដែលលោកិយកំពុងតែដេញតាម នោះអ្នកនឹងមិនអាចស្កប់ចិត្ត ហើយក៏មិនមានទំនុកចិត្ត។ ប៉ុន្តែ បើអ្នករកឃើញសេចក្តីស្រឡាញ់របស់ព្រះ ដែលបានបង្ហាញ ចេញមកតាមរយៈព្រះយេស៊ូវគ្រីស្ទ អ្នកនឹងមានទស្សនៈថ្មីមួយ អំពីសម្រស់ និងតម្លៃពិតប្រាកដរបស់អ្នក ក្នុងនាមជាស្នាព្រះ ហស្តរបស់ព្រះអង្គ។

ពេលដែលអ្នកមើលឃើញខ្លួនឯង ដូចដែលព្រះជាម្ចាស់ ទតឃើញអ្នក ការយល់ដឹងរបស់អ្នក អំពីសម្រស់ ក៏មានការ ផ្លាស់ប្តូរផងដែរ។ ការនេះនឹងនាំអ្នកធ្វើដំណើរតាមផ្លូវនៃសេរី ភាព ឲ្យស្គាល់ខ្លួនឯងច្បាស់ គឺមិនរស់នៅដើម្បីផ្គាប់ចិត្តអ្នកដទៃ នោះឡើយ។

ឡេឡាកំពុងតែមានការលំបាក ដោយសារបញ្ហានៃរូប សម្រស់របស់នាង ហើយខ្ញុំក៏មានបញ្ហានេះផងដែរ។ ទោះជា យ៉ាងណាក៏ដោយ ទស្សនៈរបស់ខ្ញុំបានផ្លាស់ប្តូរ ចាប់តាំងពីពេល ដែលខ្ញុំបានដឹងថា រូបសម្រស់របស់ខ្ញុំសំខាន់ចំពោះព្រះ គឺខុសពី ការគិតរបស់មនុស្សជាទូទៅ។ ពេលដែលខ្ញុំបានយល់អំពីជម្រៅ នៃសេចក្តីល្អ សេចក្តីស្រឡាញ់ និងព្រះគុណ ដែលព្រះទ្រង់មាន ចំពោះខ្ញុំ ខ្ញុំក៏បានចាប់ផ្តើមយល់អំពីអត្ថន័យនៃសម្រស់ តាមទ ស្សនៈដ៏ថ្មីស្រឡាង។ ជួនកាល ខ្ញុំបានទទួលរងសម្ពាធឲ្យធ្វើការ ផ្លាស់ប្តូររូបសម្រស់របស់ខ្ញុំ ដើម្បីឲ្យអ្នកដទៃចូលចិត្តខ្ញុំ។ ប៉ុន្តែ ខ្ញុំ ដឹងថា ខ្ញុំមិនចាំបាច់ត្រូវផ្លាស់ប្តូររូបរាងកាយ ដើម្បីឲ្យព្រះជាម្ចាស់ ទទួលស្គាល់ខ្ញុំនោះឡើយ ព្រោះព្រះអង្គស្រឡាញ់ខ្ញុំ ទោះខ្ញុំជា មនុស្សបែបណាក៏ដោយ។


When you discover the love of God shown through Jesus Christ, you will gain a new perspective of your true beauty and value as His special creation.
ពេលដែលអ្នករកឃើញក្ដីស្រឡាញ់ របស់ព្រះជាម្ចាស់ ដែលបានបង្ហាញមក តាមរយៈព្រះយេស៊ូវ គ្រីស្ទ អ្នកនឹងមានទស្សនៈថ្មីមួយ ដោយស្គាល់សម្រស់ និងតម្លៃពិតរបស់អ្នក ក្នុងនាមជាស្នាព្រះហស្តដ៏វិសេសរបស់ព្រះអង្គ។

ខ្ញុំបានទទួលនូវការធានាដ៏អស្ចារ្យថា ខ្ញុំមានភាពស្រស់ស្អាតដ៏ពិសេស ចំពោះព្រះជាម្ចាស់ គឺដូចដែលបទគម្ពីរទំនុកដំកើង ជំពូក ១៣៩ បានចែងថា :

*“ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់
ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ
ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់
ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ
កាលទូលបង្គំកើតមាននៅទីកំបាំង
ហើយបានសូន្យធ្វើបែបចំឡែកៗនៅទីទាបនៃផែនដី
នោះគ្រោងកាយរបស់ទូលបង្គំមិនកំបាំងនឹងទ្រង់ទេ
ព្រះនេត្រទ្រង់បានឃើញធាតុនៃទូលបង្គំ
ក្នុងកាលដែលមិនទាន់មានរូបរាងនៅឡើយ
ទាំងអស់បានកត់ទុកក្នុងបញ្ជីរបស់ទ្រង់
គឺអស់ទាំងថ្ងៃអាយុ ដែលបានតម្រូវឲ្យទូលបង្គំរស់នៅ
ក្នុងកាលដែលមិនទាន់មានថ្ងៃណាមួយនោះនៅឡើយ”។*

តើអ្នកចង់ស្វែងយល់បន្ថែម អំពីព្រះយេស៊ូវទេ? ព្រះអង្គស្គាល់អ្នក ហើយក៏ស្រឡាញ់អ្នក ទោះអ្នកមានរូបរាង ឬចំណុចខ្វះខាតយ៉ាងណាក៏ដោយ។

អ្នកអាចស្វែងយល់បន្ថែម អំពីព្រះអង្គ នៅក្នុងសៀវភៅ រឿងនៃសេចក្តីសង្ឃឹម តាម link: https://khmer-odb.org/ds/story-of-hop/ សៀវភៅនេះ នឹងប្រាប់អ្នកជាបន្ថែមទៀតថា ព្រះយេស៊ូវជានរណា ហើយបានធ្វើអ្វីខ្លះ សម្រាប់អ្នក។

For more articles by young people: ymi.today

**Our Daily Bread Ministries**
PO Box 15, Kilsyth, VIC 3137, Australia
Tel: (+61-3) 9761-7086, australia@odb.org

**Our Daily Bread Ministries Ltd**
PO Box 74025, Kowloon Central Post Office, Kowloon, Hong Kong
Tel: (+852) 2626-1102, Fax: (+852) 2626-0216, hongkong@odb.org

**ODB Indonesia**
PO Box 2500, Jakarta 11025, Indonesia
Tel: (+62-21) 2902-8950, Fax: (+62-21) 5435-1975,
indonesia@odb.org

**Daily Bread Co. Ltd**
PO Box 46, Ikoma Nara 630-0291, Japan
Tel: (+81-743) 75-8230, Fax: (+81-743) 75-8299, japan@odb.org

**Our Daily Bread Berhad**
PO Box 86, Taman Sri Tebrau, 80057 Johor Bahru, Malaysia
Tel: (+060-7) 353-1718, Fax: (+060-7) 353-4439, malaysia@odb.org

**Our Daily Bread Ministries**
PO Box 303095, North Harbour, Auckland 0751, New Zealand
Tel: (+64-9) 444-4146, newzealand@odb.org

**Our Daily Bread Ministries Foundation**
PO Box 47-260, Taipei 10399, Taiwan R.O.C.
Tel: (+886-2) 2585-5340, Fax: (+886-2) 2585-5349, taiwan@odb.org

**Our Daily Bread Ministries Thailand**
PO Box 35, Huamark, Bangkok 10243, Thailand
Tel: (+66-2) 718-5166, Fax: (+66-2) 718-6016, thailand@odb.org

**Our Daily Bread Ministries Asia Ltd**
5 Pereira Road, #07-01 Asiawide Industrial Building, Singapore 368025
Tel: (+65) 6858-0900, Fax: (+65) 6858-0400, singapore@odb.org